ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង: ៩៣/១១-អិម វ៉េ (សាខាកំពង់ឆ្នាំង)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់: ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: លីវ សុវណ្ណា
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: គង់ ផល្លះ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន អិម វ៉េ កាត់ដេរ អន្តរជាតិ លីមីធិត (សាខាកំពង់ឆ្នាំង)
អាសយដ្ឋាន ៖ ភូមិត្រពាំងចីក្បា ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០១៦ ៧០៧ ០៤៦ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក យិន ណាក់ | ប្រធានរដ្ឋបាល |
| ២- លោកស្រី Ping Liu | ប្រធានរដ្ឋបាល (សាខាកំពង់ឆ្នាំង) |
| ៣- លោក អ៊ុន ឆន្ទ: | អ្នកបកប្រែ |
| ៤- លោក ស៊ុន វណ្ណ: | អ្នកបកប្រែ |

### ២- ភាគីកម្មករនិយោជិត

ក/ឈ្មោះ ៖ - សហព័ន្ធសហជីពកម្មករកម្ពុជា
- សហជីពកម្មករនិយោជិតរោងចក្រ M & V 4
អាសយដ្ឋាន ៖ (បុរីសូឡា) ផ្ទះលេខ ៣OC ផ្លូវលេខ៣៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ ៖ ០១១ ៦៨៥ ៨២៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ឃិន សុខន | អគ្គលេខាធិការសហព័ន្ធសហជីពកម្មករកម្ពុជា |
| ២- លោក សេង ម៉េងហុង | មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា |
| ៣- លោកស្រី នួន ឆេងហួ | ប្រធានសហជីពកម្មករនិយោជិតរោងចក្រ M & V4 |
| ៤- លោកស្រី ហៀង សុភ័ក្ត្រ | អនុប្រធានសហជីពកម្មករនិយោជិតរោងចក្រ M & V 4 |
| ៥- លោកស្រី ជា រដ្ឋាវី | លេខាធិការសហជីពកម្មករនិយោជិតរោងចក្រ M & V 4 |
| ៦- លោកស្រី សឿង វណ្ណា | ទីប្រឹក្សាសហជីព |
| ៧- លោកស្រី ទឹម ស៊ីឡាត់ | ជំនួយការសហជីព |

ខ/ឈ្មោះ ៖ - សហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យជឿនលឿន

- សហជីពកម្មករនៃរោងចក្រ អិម វ៉េ ៤

អាសយដ្ឋាន ៖ ផ្ទះលេខ ៩១ D ក្រុមទី៧ ភូមិទឹកថ្លា២ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ ៖ ០១២ ៤១៧ ៣៥៧ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត-៖

| | |
|---|---|
| ១- លោក គីម ចាន់សំណាង | ប្រធានសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យជឿនលឿន |
| ២- លោក សេន សំណាង | អគ្គលេខាសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យជឿនលឿន |
| ៣- លោកស្រី នួន សំអុល | ប្រធានសហជីពកម្មករនៃរោងចក្រ អឹម វ៉េ ៤ |
| ៤- លោកស្រី ស្រឿន ចាន់ធានី | លេខាធិការសហជីពកម្មកររោងចក្រ អឹមវ៉េ ៤ |
| ៥- កញ្ញា មុំ ភារម្យ | ហិរញ្ញិកសហជីព |
| ៦- កញ្ញា អួន អៀប | ទីប្រឹក្សាសហជីព |
| ៧- កញ្ញា កែ ចាន់ថុល | សមាជិកសហជីព |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យកម្មករនៅម៉ាស៊ីនកុំព្យូទ័រ ក្រុម L2 និង D ដែលធ្វើការប្តូរវេន ចូលធ្វើការនៅវេលាម៉ោង ១ យប់ ឱ្យចូលធ្វើការនៅម៉ោងដូចអគារ M វិញ។

២- សុំឱ្យក្រុមហ៊ុនរក្សាប្រាក់លុយបាយ ២ វេន នៅដដែល ចំពោះកម្មករធ្វើការវេនយប់។

៣- សុំឱ្យក្រុមហ៊ុនជួយកែប្រែអត្តចរិកប្រធានផ្នែកឈ្មោះ ស៊ី ជឿកឈុន និង លីវ យ៉ាង ព្រោះគាត់មានការគំរាមកំហែង និងគាបសង្កត់មកលើកម្មករ និងសុំឱ្យកម្មករម្នាក់ឈ្មោះ ប្រាក់ សី ឱ្យចូលធ្វើការនៅកន្លែងដដែល។

៤- សូមឱ្យក្រុមហ៊ុនបញ្ឈប់ IE នៅរោងចក្រ M&V4 ធ្វើឱ្យកម្មករធ្លាក់ចុះនូវតម្លៃឡូតិ៍។ ពេលផ្លាស់ប្តូរម៉ាស៊ីនតម្បាញ សុំឱ្យក្រុមហ៊ុនប៉ះប៉ូវពេលវេលាសម្រាប់កម្មករ។

៦- សុំឱ្យក្រុមហ៊ុនឱ្យតម្លៃឡូត៍គ្រប់ផ្នែកអគារ ត្រូវតែសមាមាត្រនឹងប្រាក់ខែគោលកម្មករ ។

៧- តម្លៃឡូ៍ផ្នែកផុងសុំឱ្យកំណត់ឱ្យច្បាស់ពី៣-៥ថ្ងៃ ដោយកំណត់ដូចការចរចាកន្លងរួចមកហើយ សុំឱ្យអនុវត្ត ផង ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២(ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៤២៦ កប/កន ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ។

**សវនាការ និង សង្ខេបនីតិវិធី**

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ៧២ ផ្លូវលេខ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ (វេលាម៉ោង ២៖០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី៖**

នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន ១៤ ចំណុច ដែលបានទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៧ ចំណុច លើការទាមទារចំនួន ១៤ ចំណុចនោះ ។ ចំណុចមិនសះជាចំនួន ៧ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ៧ ចំណុចនេះ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ០២:០០ នាទី រសៀល ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមកាលបរិច្ឆេទ និងពេលវេលាកំណត់ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ៧ ចំណុចនេះបន្ថែម ទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន៥ចំណុច

គឺចំណុចវិវាទទី១ ចំណុចវិវាទទី៣ ចំណុចវិវាទទី៥ ចំណុចវិវាទទី៦ និង ចំណុចវិវាទទី៧ ។ ដូច្នេះ ចំណុចវិវាទដែលនៅសល់សម្រាប់ ការចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានចំនួន ២ ចំណុច គឺចំណុចទី២ និង ទី៤ ។

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ សហភាពសហជីព សហព័ន្ធសហជីព និងសហជីព ចំនួន ៦ និងប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈ នៃការយោគយល់គ្នា ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរ សំលៀកបំពាក់ ក្នុងការយល់ព្រមទទួលយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចចំពោះវិវាទអំពីសិទ្ធិ។ ចំណែកឯវិវាទអំពីផលប្រយោជន៍វិញ ភាគីដែលជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់ គ្នានេះ មានសិទ្ធិជ្រើសរើសសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ឬសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច នៅពេលសវនាការអាជ្ញាកណ្តាល។ តាមការអះអាងរបស់និយោជក ក្រុមហ៊ុន អឹម និង វី ទី៤ ខេត្ត កំពង់ឆ្នាំង នៅក្នុងសំណុំរឿងនេះ មិនមែនជាភាគីហត្ថលេខីនៃអនុស្សារណៈនេះទេ ប៉ុន្តែ ភាគីនិយោជកបានចុះកិច្ចព្រមព្រៀងទទួលយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ចំពោះវិវាទអំពីសិទ្ធិនៅក្នុងសំណុំរឿងនេះ ជាមួយនឹងភាគីកម្មករនិយោជិត។ ចំណែកឯវិវាទអំពីផលប្រយោជន៍វិញ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយ ដោយចេញសេចក្តីបង្គាប់ លើចំណុចវិវាទមិនសះជាដែលនៅសល់ទាំង ២ ខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន អឹម វី កាត់ដេរអន្តរជាតិ (សាខាកំពង់ឆ្នាំង) ផ្ទេរសិទ្ធិជូន លោក យិន ណាក់ លោកស្រី Ping Liu និងលោក ស៊ុន វណ្ណៈ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១ ។

២- សារណាឆ្លើយការពារ របស់ក្រុមហ៊ុន អឹម វី កាត់ដេរអន្តរជាតិ (សាខាទី៤) គោរពជូន លោកប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ។

៣- តារាងបើកប្រាក់ឈ្នួល។

៤- លិខិតប្តឹងជំទាស់ របស់ក្រុមហ៊ុន គោរពជូន លោកប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការប្តឹងជំទាស់ និងបំភ្លឺជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំពោះករណីកម្មករផ្នែកឆែក អាគារ១០ ដែលធ្វើមិនគ្រប់ប្រាក់គោល ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

ខ-១/សហជីពកម្មករនិយោជិត រោងចក្រ M & V 4 ៖

១- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីពកម្មករនិយោជិត រោងចក្រ M & V 4 លេខ ១៧៥០ ក.ប/វក. ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ។

២- លិខិតជំទាស់របស់សហព័ន្ធសហជីពកម្មករកម្ពុជានិងសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យជឿនលឿន តំណាងឱ្យសហជីព និងកម្មករ-កម្មការិនី រោងចក្រ M & V 4 គោរពជូន ប្រធានលេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសូមជំទាស់សារណាឆ្លើយការពារ និងឆ្លើយបំភ្លឺរឿងហេតុកើត ឡើងក្នុង ក្រុមហ៊ុនជារៀងរាល់ថ្ងៃ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ។

ខ-២/សហជីពកម្មករ នៃរោងចក្រ អឹម វ៉េ ៤ ៖

១- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីពកម្មករ នៃរោងចក្រ អឹម វ៉េ ៤ លេខ ២០៥៤ ក.ប/វក. ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ។

២- លក្ខន្តិកៈសហជីពកម្មករ នៃរោងចក្រ អឹម វ៉េ៤ ចុះបញ្ជីកាលេខ ២០៥៤ កប/វក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ។

៣- កិច្ចព្រមព្រៀងរវាងនាយកក្រុមហ៊ុន និងតំណាងកម្មករ រោងចក្រតម្បាញ អ៊ឹម និង វ៉េ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ ។

៤- លិខិតថ្លែងអំណរគុណ របស់ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតរោងចក្រ អឹមវ៉េ ៥ និងថ្នាក់ដឹកនាំ សហជីពកម្មករកាត់ដេរ នៃរោងចក្រ អឹមវ៉េ៤ ចំពោះលោកនាយកក្រុមហ៊ុន ដែលបានផ្តល់ប្រាក់ឱ្យ រង្វាន់លើកទឹកចិត្តចំនួន ៧ ដុល្លារ ជូនកម្មករដែលបានចេញពីធ្វើការមុនម៉ោង ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១ ។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម នៅរោងចក្រតម្បាញ អ៊ឹម និង វ៉េ ៤ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ។

៦- កំណត់ហេតុដោះស្រាយវិវាទនៅរោងចក្រតម្បាញ អ៊ឹម និង វ៉េ (សាខាកំពង់ឆ្នាំង) ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ។

៧- លិខិតរបស់សហជីពកម្មករនិយោជិត និង សហជីពកម្មករ រោងចក្រ អឹមវ៉េ ៤ គោរពជូន លោកប្រធាន មន្ទីរការងារ ខេត្តកំពង់ឆ្នាំង ស្តីពីសំណើរសុំជួយអន្តរាគមន៍ ដើម្បីដោះស្រាយនូវសំណើរ របស់កម្មករ ធ្វើការក្នុងរោងចក្រ អ៊ឹមវ៉េ កាត់ដេរអន្តរជាតិ ដែលមាន ១៤ ចំណុច ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ។

៨- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អឹម វ៉េ កាត់ដេរអន្តជាតិ (សាខាទី៤) ខេត្តកំពង់ឆ្នាំង ចុះបញ្ជីកាលេខ ១៣១១/០២ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២២ ។

៩- ពាក្យបណ្តឹងរបស់កម្មករចូលមកសហជីព ស្តីពីកាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១០ ដែលប្រធានផ្នែក ប្រុស ឈ្មោះ ស៊ី ជឿកឈុន បានហៅកម្មករម្តងម្នាក់ៗមកសួរអំពីឡូដែលកម្មករធ្វើរាល់ថ្ងៃ ហេតុអ្វី បានអ្នកធ្វើបានតិចម្លេះ។

១០- លិខិតស្នើសុំចរចារបស់កម្មករនិយោជិត ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០ ។

១១- កំណត់ហេតុផ្សះផ្សាវិវាទ នៅរោងចក្រ M & V 4 កំពង់ឆ្នាំង នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ ។

១២- បញ្ជីឈ្មោះកម្មករនិយោជិត។

១៣- តារាងកត់ត្រាពេលប្រជុំពិភាក្សាអំពីបញ្ចូតថ្លៃឡូត៍ អាគារ ១០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១០ ។

១៤- តារាងសម្គាល់ម៉ោងចេញចូលធ្វើការរបស់កម្មករ ។

១៥- តារាងប្រាក់ខែរបស់កម្មករ ។

១៦- បង្កាន់ដៃបើកប្រាក់ខែរបស់កម្មករ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អ៊ឹម & វ៉េ សាខាកំពង់ឆ្នាំង លេខ ៤២៦ កប/កឆ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់រោងចក្រតម្បាញ អ៊ឹម និង វ៉េ ៤ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥៥៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥៥៩ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ ។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន អ៊ឹម និង វ៉េ ទី៤ មានជួលកម្មករនិយោជិតសរុបចំនួន ៤៦៣៥នាក់ ។
- សហជីពប្រជាធិបតេយ្យជឿនលឿនមានសមាជិកប្រមាណ ១៤០០នាក់ ហើយ សហជីពកម្មករកម្ពុជាមានសមាជិកប្រមាណ ១១០០នាក់ ជាភាគីដើមបណ្តឹង នៅក្នុងសំណុំរឿងនេះ ។
- នៅក្នុងក្រុមហ៊ុន មិនមានសហជីពណាមានវិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត ទេ ។

ចំណុចវិវាទទី២: កម្មករនិយោជិតទាមទារឱ្យនិយោជករក្សាលុយបាយ២វេនចំពោះកម្មករនិយោជិតដែលធ្វើការវេនយប់

- កម្មករនិយោជិតបានលើកឡើងថា កន្លងមកក្រុមហ៊ុនបានផ្តល់លុយបាយថែមម៉ោងជាពីរ វេន គឺការថែមម៉ោងវគ្គទី១ ក្រុមហ៊ុនផ្តល់ ១០០០រៀល និង នៅវគ្គទី២ ក្រុមហ៊ុនផ្តល់លុយចំនួន ០,១២ ដុល្លារ អាមេរិក ។

- ក្រុមហ៊ុនបានលើកឡើងថា ក្រុមហ៊ុនមិនដែលចែកការផ្តល់ជូនប្រាក់ថ្លៃបាយថែមម៉ោង ជាពីរវគ្គនោះទេ។ ក្រុមហ៊ុនធ្លាប់បានផ្តល់លុយចំនួន ០,១២ ដុល្លារអាមេរិក បន្ថែមពីលើលុយបាយ ថែមម៉ោង ១០០០រៀល នោះ គឺដោយគិតថាប្រាក់ថ្លៃបាយថែមម៉ោង ១០០០រៀលនេះ គឺតិចតួចពេក ។
- បន្ទាប់ពីសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១១ ចូលជាធរមាន ភាគីនិយោជកបានផ្តល់ប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០រៀល ដោយបញ្ឈប់ការផ្តល់ជូនបន្ថែមនូវលុយចំនួន ០,១២ ដុល្លារអាមេរិក និងដោយយល់ឃើញថា ទឹកប្រាក់ ២០០០រៀលនេះ គឺមានចំនួនច្រើន និងសមរម្យជាងមុនហើយ។

ចំណុចវិវាទទី៤: កម្មករនិយោជិតទាមទារឱ្យនិយោជកឈប់ប្រើប្រព័ន្ធ IE (ប្រព័ន្ធបង្កើនចង្វាក់ផលិតកម្ម) នៅរោងចក្រ អ៊ីម និង វី ទី៤ ដែលធ្វើឱ្យតម្លៃឡូតិ៍កម្មករនិយោជិតធ្លាក់ចុះ

- កម្មករនិយោជិតបញ្ជាក់ថា គាត់ធ្វើការទាមទារក្នុងចំណុចនេះ សម្រាប់កម្មករ ផ្នែកអ៊ុត ផ្នែកប៉ះ ផ្នែកឆែក និង ផ្នែកដេរ ដែលធ្វើការងារតាមបរិមាណផលិតផល។
- ចាប់ពីខែមេសា ឆ្នាំ២០១១ មក និយោជកប្រើប្រព័ន្ធ IE (Industrial Engineering) ចំពោះកម្មករនិយោជិត ដែលដេរតាមបរិមាណផលិផល។ ប្រព័ន្ធនេះតម្រូវ ឱ្យកម្មករនិយោជិតដេរឱ្យបាន ច្រើនជាងមុនដោយប្រើរយៈពេលតិចជាងមុន។
- កម្មករនិយោជិតបានលើកឡើងថា តាំងពីប្រើប្រព័ន្ធ IE មក កម្មករនិយោជិតភាគ ច្រើន ដេរបានតិចជាងប្រាក់ឈ្នួលអប្បបរមា។ ភាគីនិយោជកបានជំទាស់នឹងការលើកឡើងនេះ ដោយបញ្ជាក់ថា កម្មករនិយោជិតភាគតិចប៉ុណ្ណោះដែលដេរមិនគ្រប់ ប្រាក់ឈ្នួលអប្បបរមា ហើយដែលនិយោជកតែងតែបង្គ្រប់ឱ្យដល់ប្រាក់ឈ្នួលគោល។
- នៅមុនពេលសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានភស្តុតាងពីកម្មករ និយោជិតដែលបញ្ជាក់ពីអត្តលេខ ឈ្មោះ ប្រាក់ឈ្នួលតាមបរិមាណដែល ពួកគាត់ដេរបាន និង ប្រាក់ឈ្នួលដែលនិយោជកបន្ថែមរបស់កម្មករនិយោជិតមួយ ចំនួននៅក្នុងឆ្នាំ ២០១០។ ដោយសារថា ចំណុចវិវាទនេះទាក់ទងនឹងការប្រើប្រព័ន្ធ IE នៅក្នុងឆ្នាំ២០១១ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាឯកសារនេះទេ។
- នៅក្រោយថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលភស្តុតាងបន្ថែមពីភាគី កម្មករនិយោជិត គឺតារាងបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិតផ្នែកឆែក ប្រចាំខែកក្កដា ឆ្នាំ២០១១ សរុបចំនួន ១២២នាក់។ ក្នុងចំណោម កម្មករនិយោជិត ១២២នាក់ មានកម្មករប្រមាណ ៦០% ដេរមិនគ្រប់ប្រាក់ឈ្នួលអប្បបរមា បូករួមទាំងការធ្វើការថែមម៉ោងស្ទើរតែទាំងអស់ ហើយដែលនិយោជកបានបង្គ្រប់ឱ្យ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទទួលតារាងប្រាក់ឈ្នួលរបស់កម្មករនិយោជិត ផ្នែកឆែក ពីភាគីនិយោជកប្រចាំខែកក្កដា ឆ្នាំ២០១១ដែរ អំពីកម្មករនិយោជិត ចំនួន២៣នាក់ ដែលបង្ហាញថា កម្មករប្រមាណ ៥០% ដេរមិនគ្រប់ប្រាក់ឈ្នួល អប្បបរមា បូករួមទាំងការធ្វើការថែមម៉ោង ហើយដែលនិយោជកបានបង្គ្រប់ឱ្យ។ ភាគីនិយោជកបានជំទាស់នឹងភស្តុតាងរបស់កម្មករនិយោជិត ស្តីពីតារាងបើកប្រាក់ឈ្នួលរបស់

កម្មករនិយោជិតផ្នែកនែក ប្រចាំខែកក្កដា ឆ្នាំ២០១១ សរុបចំនួន ១២២នាក់ ដែលបង្ហាញថា មានកម្មករប្រមាណ ៦០% ដេរមិនគ្រប់ ប្រាក់ឈ្នួលអប្បបរមាដែលនិយោជកបង្គប់ឱ្យ។ ក្រៅពីលើកឡើងថាភស្តុតាងនេះ មិនអាចទទួលយកបាន និយោជកមិនបានបង្ហាញមូលហេតុ ឬ អំណះអំណាងបន្ថែម ដើម្បីជំទាស់នឹងភស្តុតាង របស់កម្មករនិយោជិតទេ។

- ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលភស្តុតាងពីកម្មករនិយោជិតដើម្បីគាំទ្រការទាមទារសម្រាប់កម្មករដទៃ ក្រៅពីផ្នែកនែកនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាការទាមទារនេះសម្រាប់តែផ្នែកនែកប៉ុណ្ណោះ។

**ហេតុផលនៃសេចក្តីសម្រេច:**

ចំណុចវិវាទទី២: កម្មករនិយោជិតទាមទារឱ្យនិយោជករក្សាលុយបាយ២វេនចំពោះកម្មករនិយោជិតដែលធ្វើការវេនយប់

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើ ការទាមទារក្នុងចំណុចនេះជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "វិវាទអំពីសិទ្ធិ គឺជា វិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារូមណាមួយចែង ពីការទាមទារនោះ "។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ០៥/១១-អ៊ីម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ១៣/១១-ហ្គូល កាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៤/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ពោលគឺវិវាទអំពីសិទ្ធិ ជាវិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់កិច្ចព្រមព្រៀង ឬអនុសញ្ញារូមណាមួយចែងពីការទាមទារនោះ។

ក្នុងករណីនេះកម្មករនិយោជិតទាមទារឱ្យនិយោជករក្សាលុយបាយថែមម៉ោង ២វេន ចំពោះកម្មករនិយោជិតដែលធ្វើការវេនយប់ហើយវិវាទនេះ មានចែងក្នុងសេចក្តីជូនដំណឹង០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១១ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាវិវាទនេះជា វិវាទអំពីសិទ្ធិ ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថាតើ ភាគីនិយោជកមានកាតព្វកិច្ចផ្តល់ជូនបន្ថែមនូវលុយចំនួន ០,១២ ដុល្លារអាមេរិក ពីលើប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០រៀល ចំពោះកម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង ដែរឬទេ?

ចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១១ បានចែងថា " កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬ ទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ។"

យោងតាមអង្គហេតុ ក្រុមហ៊ុនធ្លាប់បានផ្តល់លុយចំនួន ០,១២ ដុល្លារអាមេរិក បន្ថែមពីលើលុយបាយថែមម៉ោង ១០០០រៀល នោះ គឺដោយគិតថាប្រាក់ថ្លៃបាយថែមម៉ោង ១០០០រៀលនេះគឺតិចតួចពេក។ បន្ទាប់ពីសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ខាងលើ ចូលជាធរមាន ភាគីនិយោជកបានផ្តល់ប្រាក់ថ្លៃបាយថែម

ម៉ោងចំនួន ២០០០រៀល ដោយបញ្ឈប់ការផ្តល់ជូនបន្ថែមនូវលុយចំនួន ០,១២ ដុល្លារអាមេរិក និងដោយយល់ឃើញថា ទឹកប្រាក់ ២០០០រៀលនេះ គឺមានចំនួនច្រើន និងសមរម្យជាងមុនហើយ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីនិយោជកបានអនុវត្តតាមស្មារតីនៃ សេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ រួចហើយ ដោយធ្វើការផ្តល់ប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០រៀល ចំពោះកម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង ។ បន្ថែមពីលើការអនុវត្តតាមសេចក្តីជូនដំណឹងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ឃើញថា និយោជកមានហេតុផលសមរម្យក្នុងការឈប់ផ្តល់បន្ថែមនូវលុយចំនួន ០,១២ ដុល្លារអាមេរិក ព្រោះទឹកប្រាក់ ២០០០រៀលនេះ គឺមានចំនួនច្រើន និងសមរម្យជាងមុនហើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកគ្មានកាតព្វកិច្ចផ្តល់ជូនបន្ថែមនូវលុយចំនួន ០,១២ ដុល្លារអាមេរិក ពីលើប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០រៀល នោះទេ ។

សុរបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធការទាមទារឱ្យនិយោជកផ្តល់ជូនបន្ថែមនូវលុយចំនួន ០,១២ ដុល្លារអាមេរិក ពីលើប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០រៀល ចំពោះកម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង ។

ចំណុចវិវាទទី៤: កម្មករនិយោជិតទាមទារឱ្យនិយោជកឈប់ប្រើប្រព័ន្ធ IE នៅរោងចក្រ អឹម និង វ៉េ ទី៤ ដែលធ្វើឱ្យតម្លៃឡូត៍កម្មករនិយោជិតធ្លាក់ចុះ

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារក្នុងចំណុចនេះ ជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ដោយសារការទាមទារក្នុងចំណុចនេះ ជាការទាមទារទាក់ទងនឹងសិទ្ធិគ្រប់គ្រង និង ដឹកនាំរបស់និយោជកពាក់ព័ន្ធជាមួយនឹងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត ដែលមានចែងក្នុងច្បាប់ស្តីពីការងារ ហេតុនេះចំណុចវិវាទនេះ ជាចំណុចវិវាទអំពីសិទ្ធិ។ (ទាក់ទងនឹង ការបកស្រាយវិវាទអំពីសិទ្ធិ សូមមើលហេតុផលចំណុចវិវាទទី១ខាងលើ) ។

ក្នុងករណីនេះ និយោជកបានប្រើប្រព័ន្ធ IE(Industrial Enginerring/ ប្រព័ន្ធបង្កើនចង្វាក់ផលិតកម្ម) ចំពោះកម្មករនិយោជិតដែលដេរតាមបរិមាណផលិតផល ចាប់ពីខែមេសា ឆ្នាំ២០១១ មក ។ ប្រព័ន្ធនេះតម្រូវឱ្យកម្មករនិយោជិតដេរឱ្យបានច្រើនជាងមុនដោយប្រើរយៈពេលតិចជាងមុន ។ កម្មករនិយោជិតទាមទារឱ្យនិយោជកឈប់ប្រើប្រព័ន្ធនេះ ព្រោះវាធ្វើឱ្យកម្មករនិយោជិតភាគច្រើនដេរមិនគ្រប់ប្រាក់ឈ្នួលអប្បបរមា ប៉ុន្តែ ភាគីនិយោជកមិនយល់ព្រម ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថាតើនិយោជកមានកាតព្វកិច្ចបញ្ឈប់ការប្រើប្រព័ន្ធ IE ដែរឬទេ ប្រសិនបើប្រព័ន្ធនេះធ្វើឱ្យកម្មករនិយោជិតភាគច្រើនមិនបានទទួលនូវប្រាក់ឈ្នួលយ៉ាងតិច ស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវវិធានាហើយដែលកំណត់សម្រាប់កម្មករនិយោជិត?

មាត្រា២ នៃច្បាប់ស្តីពីការងារចែងថា " រូបវន្តបុគ្គល ឬនីតិបុគ្គលជាសាធារណៈ ឬឯកជន ទាំងអស់នឹងទុកជានិយោជកដែលបង្កើតសហគ្រាសតាមន័យនៃច្បាប់នេះ លុះត្រាតែបុគ្គលទាំង នោះមានប្រើកម្មករនិយោជិត

ម្នាក់ ឬច្រើននាក់ ទោះមិនបានជាប់លាប់ក៏ដោយ ។

សហគ្រាសនីមួយៗអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះមានប្រើមនុស្ស មួយក្រុម ធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល ។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក ។ ... "

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា២នេះ មានន័យថា ភាគីនិយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុនដរាបណាការចាត់ចែង និងគ្រប់គ្រងនោះ សមហេតុផល ហើយស្របច្បាប់ ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៤/០៤-សណ្ឋាគាររ៉ាហ្វល ហ្វ្រង់ ដង់គរ ហេតុផលចំណុចវិវាទទី១ ១៨/០៨-ជី អេច ជី ២០/០៦-ញូស្តារ ហេតុផលចំណុចវិវាទទី៥ ១០៨/០៦-ទ្រីណុងហ្គាល់ កូម៉ាវ៉ា ហេតុផលចំណុចវិវាទទី១ ១៧/០៧-ឆាមថិចថាយ ហេតុផលចំណុចវិវាទទី៣ និងលេខ ១១៦/០៧-ហ្គ្រេស សាន់ ហេតុផលចំណុចវិវាទទី២)

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលឯកភាពលើការបកស្រាយខាងលើ គឺ និយោជកមានសិទ្ធិក្នុងការផ្លាស់ប្តូរការអនុវត្ត ។ ក្នុងករណីនេះ សិទ្ធិចាត់ចែង និង គ្រប់គ្រងរបស់និយោជក គឺសិទ្ធិក្នុងការផ្លាស់ប្តូរមកប្រើប្រព័ន្ធ IE ចំពោះកម្មករនិយោជិតដែលដេរតាមបរិមាណផលិតផល ដរាបណាការផ្លាស់ប្តូរដោយនិយោជកនេះ សមហេតុផល ហើយស្របច្បាប់ ។

មាត្រា១០៨ នៃច្បាប់ស្តីពីការងារចែងថា " ចំពោះការងារម៉ៅការ ឬតាមបរិមាណផលិតផល ទោះធ្វើនៅរោងជាង ឬនៅលំនៅក៏ដោយ ប្រាក់ឈ្នួលត្រូវគិតយ៉ាងណាឱ្យកម្មករនិយោជិត ដែលមានការប៉ិនប្រសប់មធ្យម ធ្វើការជាធម្មតា បានទទួលក្នុងថិរវេលាធ្វើការដដែល នូវប្រាក់ឈ្នួលយ៉ាងតិច ស្មើនឹងប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មករនិយោជិត ។ "

ប៉ុន្តែ យោងតាមចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤៩/១០ កប/ស.ជ.ណ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០ "កំណត់ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងចំនួន ៥៦ (ហាសិបប្រាំមួយ) ដុល្លារ អាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតសាកល្បងពី ១ខែ ទៅ ៣ខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៤៥ ដុល្លារ បូកប្រាក់តម្លើង ៥ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ដុល្លារ ស្មើ៥៦ដុល្លារ) ។ ចប់រយៈពេលសាកល្បង កម្មករ និយោជិតពេញសិទ្ធិ ត្រូវទទួលប្រាក់ឈ្នួលអប្បបរមាចំនួន ៦១ (ហុកសិបមួយ) ដុល្លារ អាមេរិក ក្នុងមួយខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៥០ដុល្លារ បូកប្រាក់តម្លើង ៥ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព ៦ដុល្លារ ស្មើ៦១ ដុល្លារ) ។

៣. ចំពោះកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល (ដេរស៊ីបុង) ត្រូវបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួលបាននោះ លើសពីចំនួនប្រាក់ឈ្នួលដែលមានចែងក្នុងចំណុចទី២ ខាងលើ ត្រូវទទួលបានតាមការលើសនោះ ។ ប្រសិនបើទាបជាង និយោជកត្រូវបន្ថែម ឱ្យគ្រប់ចំនួន ៥៦ដុល្លារ អាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតធ្វើការសាកល្បង និងចំនួន៦១ ដុល្លារ អាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ ។ "

នៅក្នុងសេចក្ដីបង្គាប់មុនៗរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាល សំរេចថា "និយោជក មានសិទ្ធកំណត់ ឬផ្លាស់ប្ដូរតម្លៃបុង ក៏ប៉ុន្តែក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានសំរេចថា ត្រូវកំណត់ធ្វើយ៉ាងណា ឱ្យតម្លៃបុងឱ្យកម្មករនិយោជិតដែលមានការប៉ិនប្រសប់មធ្យម ធ្វើការធម្មតាអាចទទួលបានប្រាក់ឈ្នួលអប្បបរមា ។" (សូមមើលសំណុំរឿងលេខ ០៣/០៥-ហ្គាអ៊ីង ដ្រាហ្គុង ចំណុចវិវាទទី៦ សំណុំរឿងលេខ ៤១/០៥-វីយូឡេទ ចំណុចវិវាទទី៨ សំណុំរឿងលេខ៤៤/០៦-ហ្គោលហ្វេម ចំណុចវិវាទទី១ ) ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏ឯកភាពលើការបកស្រាយខាងលើ គឺ ចំពោះការងារ តាមបរិមាណផលិតផល និយោជកមានសិទ្ធិក្នុងការផ្លាស់ប្ដូរមកប្រើប្រព័ន្ធ IE ចំពោះកម្មករនិយោជិតដែលដេរ តាមបរិមាណផលិផល ប៉ុន្តែគាត់មានកាតព្វកិច្ចក្នុងការ គិតប្រាក់ឈ្នួលយ៉ាងណាឱ្យកម្មករនិយោជិត ដែលមានការប៉ិនប្រសប់មធ្យមធ្វើការជាធម្មតា បានទទួលក្នុងចិរវេលាធ្វើការដដែល នូវប្រាក់ឈ្នួលយ៉ាងតិច ស្មើនឹងប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មករនិយោជិត ពោលគឺ ៦១ដុល្លារ អាមេរិក ក្នុងមួយខែ ។

ផ្អែកតាមអង្គហេតុ ក្នុងចំណោមកម្មករនិយោជិត១២២នាក់ នៅផ្នែកឆែក មានកម្មករ ប្រមាណ ៦០% ដេរមិនគ្រប់ប្រាក់ឈ្នួលអប្បបរមា បូករួមទាំងការធ្វើការថែមម៉ោង ស្ទើរតែ ទាំងអស់ ហើយដែលនិយោជកបានបង្គ្រប់ឱ្យ ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ទោះបីជានិយោជកបានបង្គ្រប់ឱ្យដល់ប្រាក់ឈ្នួលអប្បបរមា ចំពោះកម្មករប្រមាណ ៦០% នោះក៏ដោយ ក៏ការគ្រប់គ្រង និងដឹកនាំ ដោយប្រែមកប្រើប្រព័ន្ធ IE នេះ មិនសមហេតុផល និងស្របច្បាប់ដែរ ព្រោះ កម្មករប្រមាណ ៦០% ជាចំនួនភាគច្រើន ដែលដេរមិនគ្រប់ប្រាក់ឈ្នួល ទោះបីភាគច្រើនធ្វើការងារថែមម៉ោងស្ទើរតែទាំងអស់ក៏ដោយ ។ ត្រង់នេះបញ្ជាក់ឱ្យឃើញថា ប្រសិនបើមិនគិតកម្រៃពីការងារថែមម៉ោងប្រាក់ឈ្នួលរបស់កម្មករនិយោជិតទេ ប្រាក់ឈ្នួលដែលពួកគេទទួលបាន រិតតែទាបជាងនេះទៅទៀត ។

សរុបសេចក្ដីមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បដិសេធការទាមទាររបស់ កម្មករនិយោជិតឱ្យនិយោជកឈប់ប្រើប្រព័ន្ធ IE នៅរោងចក្រ អឹម និង វ៉េ ទី៤ ប៉ុន្តែ បង្គាប់ឱ្យនិយោជក រៀបចំ និង ត្រួតពិនិត្យប្រព័ន្ធ IE នេះឡើងវិញដើម្បីធានាថា កម្មករនិយោជិតដែលមានការប៉ិនប្រសប់មធ្យមចាប់ពី៦០ភាគរយឡើងទៅ ធ្វើការជាធម្មតា បានទទួលក្នុងចិរវេលាធ្វើការដដែល នូវប្រាក់ឈ្នួលយ៉ាងតិច ស្មើនឹងប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានាដោយច្បាប់ ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចដូចតទៅ:

## សម្រេច និង បង្គាប់

**១-សេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:**

ចំណុចវិវាទទី២: បដិសេធការទាមទារ របស់កម្មករនិយោជិត ឱ្យនិយោជកបន្តផ្ដល់ជូន បន្ថែមនូវលុយចំនួន ០,១២ ដុល្លារអាមេរិក ពីលើប្រាក់ថ្លៃបាយថែមម៉ោងចំនួន ២០០០រៀល ចំពោះកម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង ។

ចំណុចវិវាទទី៤: - បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកឈប់ប្រើប្រព័ន្ធ IE នៅរោងចក្រ អឹម និង វ៉េ ទី៤ (សាខាខេត្តកំពង់ឆ្នាំង) ។

- បង្គាប់ឱ្យនិយោជករៀបចំ និង ត្រួតពិនិត្យប្រព័ន្ធ IE នេះឡើងវិញ ដើម្បីធានាថា កម្មករនិយោជិតដែលមានការប៉ិនប្រសប់មធ្យមចាប់ពី៦០ភាគរយឡើងទៅ ធ្វើការជាធម្មតា បានទទួលក្នុងថិរវេលាធ្វើការដដែល នូវប្រាក់ឈ្នួលយ៉ាងតិច ស្មើនឹងប្រាក់ឈ្នួល អប្បបរមា ដែលត្រូវធានាដោយច្បាប់ ។

ប្រភេទនៃសេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:

សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសេចក្ដីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្ដង ដោយយោងតាមអនុស្សារណៈនៃការ យោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០ ។

**២- សេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ : គ្មាន**

ប្រភេទនៃសេចក្ដីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍:

សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសេចក្ដីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្នុងរយៈពេលនេះទេ ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក:

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត:

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល:

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា: ------------------------------------